

# បុណ្យប្រពៃណី (ខ្ញុំមកដល់ហើយ)

Tantra Rahmadia

Amalia Dian

Let's Read

The Asia Foundation



«ពួកគេមាននំមួយប្រភេទ ឈ្មោះថា នំជីប៉ាងរូបកង់! ខ្ញុំចូលចិត្តនំនោះណាស់!»
«ខ្ញុំបានញ៉ាំប្រហិតម្យ៉ាងដែលធំប៉ុនផ្លែដូង!»
«ពួកយើងបានឃើញឆត្រធំៗចម្រុះពណ៌!»
នីតាបានស្តាប់មិត្តភក្តិរបស់នាងកំពុងជជែកគ្នាអំពីពិធីបុណ្យ។ នាងឆ្ងល់ថា តើពិធីបុណ្យនោះជាអ្វីទៅ?



រំពេចនោះ នីតាក៏ប្រញាប់រត់ទៅផ្ទះដើម្បីសួរម្តាយរបស់នាង។ នាងឆ្ងល់យ៉ាងខ្លាំងអំពីពិធីបុណ្យដែលមិត្តរបស់នាងបានប្រាប់។ នីតាបានសួរទៅម្តាយរបស់នាងថា «ម៉ាក់! តើនំជីប៉ាងរូបកង់ជាអ្វីទៅ?» ។ ម្តាយរបស់នាងឆ្លើយថា «វាគឺជានំមួយប្រភេទដែលធ្វើអំពីអង្ករណាកូន!» ។ នីតាក៏បន្តសួរ «ម៉ាក់! ពេលយើងទៅចូលរួមក្នុងពិធីបុណ្យមួយនោះ តើខ្ញុំអាចសុំទិញវាបានដែរទេ?»។ ម្តាយនីតាងក់ក្បាលយល់ព្រម។ «ជយោ!!!!» នីតាស្រែកខ្លាំងៗដោយសប្បាយចិត្ត។



នៅថ្ងៃបន្ទាប់ នីតាភ្ញាក់ពីដំណេកដោយសប្បាយរីករាយ។ នាងចង់ទៅចូលរួមក្នុងពិធីបុណ្យមួយនោះខ្លាំងណាស់ ប៉ុន្តែនាងត្រូវធ្វើការងារផ្ទះឱ្យរួចរាល់សិន។ ទោះបីជានីតាធ្វើការងារផ្ទះហត់នឿយយ៉ាងណាក៏ដោយ ក៏នាងមិនឈប់សម្រាកដែរ។



ផាប់! ផាប់! ផាប់! ផាប់!
នីតាបានឮសំឡេងដែលឪពុករបស់នាងកំពុងទះដើមត្នោត ដើម្បីយកទឹកស្ករត្នោតបន្ថែមទៀត។ នាងចូលចិត្តសូរសំឡេងនោះណាស់។
នីតាបានហៅឪពុករបស់នាងថា «ប៉ា! អញ្ជើញទៅពិសារអាហារពេលព្រឹក។ ព្រឹកនេះ យើងមានទឹកស្លែ និងសម្លការីតៅហ៊ូ!»។
ជយោ! នីតាបានធ្វើការងារផ្ទះរួចរាល់ហើយ។



នៅពេលនីតាចូលទៅក្នុងផ្ទះវិញ នាងបានឃើញម្ដាយរបស់នាងកំពុងអង្គុយកូរស្ករត្នោតនៅឯផ្ទះបាយ។ ម្ដាយនីតាប្រាប់ថា «នីតា! កូនទៅយកអុសមកថែមទៀត ហើយជួយបង្កាត់ភ្លើងឱ្យម៉ាក់ផង!» ។



នីតាបានទៅប្រមូលយកអុសឱ្យម្ដាយនាង។
«អឺះ...អឺះ! វាធ្ងន់ខ្លាំងណាស់!» នីតាខំប្រឹងក្រោកឈរឡើង។
«អូយ!» ស្រាប់តែនាងស្រែកឡើងយ៉ាងខ្លាំង ព្រោះស្រមោចដ៏ធំមួយបានខាំកែងជើងរបស់នាង!



នៅក្នុងផ្ទះបាយ ភ្លើងចង្ក្រានស្ទើរតែរលត់អស់ទៅហើយ។
«ភ្លើង...កុំទាន់រលត់អី!» នីតានិយាយបណ្តើរ ដាក់អុសបន្ថែម
ទៅក្នុងចង្ក្រានបណ្តើរ។ បន្ទាប់មក នាងបានយកបំពង់ឬស្សី
ដើម្បីផ្លុំរងើកភ្លើងឱ្យឆេះឡើងវិញ។ វូប..វូប...វូប!
“ជយោ! ភ្លើងចង្ក្រានឆេះវិញហើយ!”



ម្តាយនីតាបានកាត់ស្កររត្នោតទៅជាដុំតូចៗ ដូច្នេះនីតាត្រូវយកខ្សែដើមចេកទៅចងវាជា១០ដុំ ១០ដុំចូលគ្នា។

នាងចាប់ផ្តើមនឿយហត់ខ្លាំងណាស់ ហើយនាងក៏ស្រាប់តែវិលមុខមួយរំពេច។



ទីបំផុតឪពុកនីតាក៏បានមកផ្ទះវិញ!
ម្ដាយនីតាក៏ធ្វើស្ករត្នោតខាប់រួចរាល់ដែរ។
ស្ករត្នោតទាំងដុំៗ ក៏បានវេចខ្ចប់ដាក់នៅក្នុងកន្ត្រករួចហើយដែរ។
ពេលនេះ ស្ករត្នោតទាំងនេះអាចយកទៅលក់បានហើយ។
"ពិធីបុណ្យអើយ! ខ្ញុំនឹងទៅលេងឯង! ខ្ញុំចង់ទិញនំជីប៉ាងរូបកង់!" នីតានិយាយដោយសប្បាយរីករាយ។



នីតាបានបន្តច្រៀងនៅមុខផ្ទះថា     ពិធីបុណ្យអើយ ខ្ញុំនឹង
ទៅលេងឯងហើយ! តោះទៅទិញនំជីប៉ាងរូបកង់!”
វត្ថុងងឹតមួយបានជះពន្លឺយ៉ាងភ្លឺចិញ្ចាចពីចម្ងាយមក។
វាមានចលនារវីករវើក កំពុងឆ្លងកាត់ផ្លូវគ្រហិកគ្រហុក។
”ឡានមកដល់ហើយ!” នីតាស្រែកបណ្តើរ គ្រវីដៃបណ្តើរ។



ឡានទោះបានធ្វើដំណើរកាត់ចម្ការអំពៅនិងទីទួលដុំថ្ម ឆ្លងកាត់ស្ពានឈើ និងព្រៃកាប៉ុកដែលមានដើមឈើធំៗ។ ទោះបីជាធ្វើដំណើរនៅលើផ្លូវដែលមានខ្យល់បក់ក៏ដោយ ក៏អ្នកដំណើរទាំងអស់បានច្រៀងលេងកម្សាន្តយ៉ាងសប្បាយរីករាយ។



នៅពេលមកដល់កន្លែងបុណ្យ គ្រាន់តែឡានឈប់ភ្លាម ក្មេងៗ បាននាំគ្នារត់ចេញពីឡានយ៉ាងលឿន។ ចំណែកនីតាវិញចុះពីឡានយឺតៗ ដោយប្រុងប្រយ័ត្ន តែបន្តិចក្រោយមកនាងក៏រត់ទៅយ៉ាងលឿននឹងគេដែរ។ នាងរត់លឿនពេក ស្ទើរតែជ្រុះបាត់លុយ ១ម៉ឺន៤ពាន់រូពី ដែលម្ដាយនាងបានឱ្យមកទុកទិញចំណី។



នីតាបានឃើញវត្ថុជាច្រើនដែលនាងមិនធ្លាប់បានឃើញពីមុន។ នាងរវល់ងាកមើលឆ្វេង មើលស្តាំដោយអារម្មណ៍រំភើប។

«អ្នកបង្ហាញម៉ូតទាំងអស់នោះខ្ពស់ៗម្ល៉េះ!»

«សម្លៀកបំពាក់របស់ពួកគាត់ស្រស់ស្អាតណាស់!»

«សូរសំឡេងទភ្លេងអង់ឃ្លុងនេះពីរោះណាស់!»



”ពិតជាអស្ចារ្យមែន!” នីតាដើរថយក្រោយបន្តិច ហើយមើលទៅខាងលើ។

”ឆត្រយក្ស! ពិតជាធំហើយអស្ចារ្យណាស់! ពណ៌របស់ឆត្រទាំងនេះពិតជាមានភាពទាក់ទាញ និងស្រស់ស្អាតមែន!”។



សេះជ័រទាំងនេះវិលចុះវិលឡើងជារង្វង់។ មនុស្សម្នានាំគ្នាឈរតម្រង់ជួរយ៉ាងវែងដើម្បីចាំដល់វេនជិះសេះ។ នីតាបានទៅឈរតម្រង់ជួរជាមួយគេហើយខំធ្វើខ្លួនឱ្យក្លាហាន។

នីតាជិះសេះឡើងចុះជាមួយនឹងចង្វាក់ភ្លេងរបស់វា។ ការជិះសេះវិលពិតជារំភើបណាស់!



នីតាបានដើរជុំវិញពិធីបុណ្យជាមួយម្ដាយយ៉ាងរំភើបរីករាយ។ ម្ដាយរបស់នីតាដើរលេងបណ្ដើរ លក់ស្ករត្នោតឱ្យអ្នកលក់អាហារបណ្ដើរ។ ស្រាប់តែនីតាបានធុំក្លិនអ្វីម៉្យាងយ៉ាងទាក់ទាញ។

ម្ដាយរបស់នីតាបានប្រាប់នាងថា ”គេប្រើស្ករត្នោតជាគ្រឿងផ្សំមួយយ៉ាងសំខាន់មិនអាចខ្វះបានទៅលើម្ហូបអាហារភាគច្រើន” ។



អ្នកលក់ភេសជ្ជៈម្នាក់កំពុងលាយភេសជ្ជៈយ៉ាងប៉ិនប្រសប់។
ម្ដាយរបស់នីតាបានប្រាប់ថា "រសជាតិដ៏ឈ្ងុយឆ្ងាញ់របស់
ភេសជ្ជៈទាំងនោះគឺបានដោយសារតែស្ករត្នោត"។
ស្ករត្នោតរបស់ម្ដាយនីតាគឺល្បីល្បាញថាមានរសជាតិឆ្ងាញ់ និង
មានតម្លៃមិនថ្លៃឡើយ។



នីតាបានដើរជុំវិញពិធីបុណ្យដោយរកមើលអាហារសម្រន់ផ្សេងៗ។ នាងអានគ្រប់ផ្លាកសញ្ញានីមួយៗដែលនាងបានឃើញ។

"អូ ខ្ញុំគិតថាប្រហិតផាវនេះប្រាកដជាមានបង្កប់ផាវមែនទែននៅខាងក្នុងហើយ! ដោយហេតុថាវាមានទឹកម្ទេសនៅក្នុងសាច់ប្រហិតនោះ!"



រំពេចនោះ នីតាស្រាប់តែនៅឈរស្ងៀមទ្រឹង ព្រោះនាង
បានឃើញរបស់អ្វីម៉្យាង។
នោះ...នោះគឺជា  នំជីប៉ាងរូបកង់!




អូ! វាពុំមែនជាកង់ពិតប្រាកដទេ គឺវាគ្រាន់តែមានរាងជារូបកង់ប៉ុណ្ណោះ។

"តើកង់នេះតម្លៃប៉ុន្មានដែរលោកពូ?"

អ្នកលក់បានឆ្លើយថា "មួយម៉ឺនប្រាំពាន់រូពី ណាក្មួយ"។

នីតាពុំមានលុយគ្រប់គ្រាន់សម្រាប់ទិញនំនោះទេ។

ស្រាប់តែ នាងនឹកឃើញគំនិតមួយ។




«ចុះមួយនេះវិញ តើមានតម្លៃប៉ុន្មានដែរ លោកពូ?» នីតាបន្តសួរ ដោយនាងបានចង្អុលទៅនំជីប៉ាងដែលមានរូបរាងផ្សេងទៀត។ អ្នកលក់ឆ្លើយ «មួយនេះមានតម្លៃត្រឹមតែមួយម៉ឺនរៀល ប៉ុណ្ណោះ!» ។

«បើដូច្នេះ តើខ្ញុំអាចទិញនំមួយនេះបានទេ?»



នីតាចង់បាននំជីប៉ាងរូបកង់ ប៉ុន្តែឥឡូវនាងបែរជាបាននំជីប៉ាងរូបមេអំបៅទៅវិញ។ ទោះបីជាយ៉ាងណា ក៏នាងសប្បាយចិត្តដែរ។

”មេអំបៅ តោះយើងហើរ!” នាងស្រែកឡើងដោយសប្បាយរីករាយ។



ម្ដាយរបស់នីតាក៏សប្បាយចិត្តណាស់ដែរ ព្រោះគាត់បានលក់ស្ករត្នោតអស់រលីង។
នីតាចងចាំមិនភ្លេចទេ នូវភាពសប្បាយរីករាយនៅក្នុងពិធីបុណ្យមួយនេះ។ នាងស្រឡាញ់នំជីប៉ាងរូបមេអំបៅយ៉ាងខ្លាំង ហើយនាងឱបវាជាប់រហូតពេលត្រឡប់ទៅផ្ទះវិញ។



ពាក្យសំខាន់ៗមួយចំនួន

នំជីប៉ាងរូបកង់ - ជានំផ្អែមម៉្យាងរបស់ប្រទេសឥណ្ឌូនេស៊ីដែលធ្វើមកពីអង្ករ ហើយមានរាងដូចកង់។

រូពី - ជារូបិយបណ្ណផ្លូវការរបស់ប្រទេសឥណ្ឌូនេស៊ី។

ព្រៃកាប៉ុក - ព្រៃដែលមានដើមឈើធំៗ ខ្ពស់ៗ ហើយដុះនៅក្នុងព្រៃដែលមានភ្លៀងធ្លាក់ច្រើននៅប្រទេសឥណ្ឌូនេស៊ី។

អង់ឃ្លុង - ជាឧបករណ៍ភ្លេងម៉្យាងដែលធ្វើពីបំពង់ឫស្សី ទុកសម្រាប់ប្រគំនៅក្នុងពិធីប្រពៃណីផ្សេងៗ។ អង់ឃ្លុងមានដើមកំណើតនៅកោះជ្វាខាងលិចនៃប្រទេសឥណ្ឌូនេស៊ី៕

សៀវភៅនេះត្រូវបានផលិតដោយមូលនិធិអាស៊ី ដោយមាន ការឧបត្ថម្ភគាំទ្រពីក្រុមហ៊ុន មូលនិធិសប្បុរសធម៌អេស្ទេឡ ឌី។ រឿងទាំងនេះ ត្រូវបាននិពន្ធឡើងដោយក្រុមស្ត្រីដែល មានគំនិតច្នៃប្រឌិតក្នុងការបង្ហាញអំពីតថភាពជាក់ស្តែងអំពី ភាពមានបាន និងបទពិសោធផ្សេងៗគ្នារបស់ស្ត្រីនៅក្នុងសង្គម នៃប្រទេសឥណ្ឌូនេស៊ី។ មូលនិធិលីតារ៉ា គឺជាអង្គការដែល ដឹកនាំសិក្ខាសាលាក្នុងការបង្កើតសៀវភៅ និងរៀបរៀង ព្រម ទាំងឌីហ្សាញសៀវភៅ។ មូលនិធិ លីតារ៉ា ជាអង្គការមិនស្វែងរក ប្រាក់ចំណេញដែលមានគោលបំណងបណ្តុះគំនិតអក្សរសាស្ត្រ តាមរយៈអក្សរសិល្ប៍កុមារ។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Festival, Aku Datang! (Festival, Here I Come!)*, Author: Tantra Rahmadia. Illustrator: Amalia Dian. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC-BY-NC-4.0.

This work is a modified version of the original story. © The Asia Foundation, 2021. Some rights reserved. Released under CC-BY-NC-4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/
Contributing translators: